**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# សុន្ទរកថា
# លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីដាក់ឱ្យដំណើរការជាផ្លូវការ "សេវាទូទាត់រហ័ស"

នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ (City Hall)
ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦

សូមគោរព ៖

- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានចូលរួមក្នុងពិធីដាក់ឱ្យដំណើរការជាផ្លូវការសេវាទូទាត់រហ័ស ដែលជាសមិទ្ធិផលថ្មីសម្រាប់ប្រទេសកម្ពុជា ។ ក្នុងនាមធនាគារជាតិនៃកម្ពុជា និងក្នុងនាមរូបខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃយ៉ាងខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានសមាជិកដែលបានបង្កើតនិងអភិវឌ្ឍសេវានេះឡើង ដើម្បីជាមធ្យោបាយដ៏ងាយស្រួលសម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទាំងអស់អនុវត្តប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់សងប្រាក់ឆ្លងគ្រឹះស្ថានជាប្រាក់រៀលសម្រាប់អតិថិជនរបស់ខ្លួន ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា** ឱ្យបានជ្រាបថា ប្រព័ន្ធទូទាត់គឺជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុដ៏សំខាន់មួយរបស់ប្រទេសដែលសម្រួលដល់ចរាចរសាច់ប្រាក់ជាអេឡិចត្រូនិកក្នុងសេដ្ឋកិច្ច ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកចម្រើនគួរអោយកត់សម្គាល់ជាមួយនឹងកំណើនជារៀងរាល់ឆ្នាំ ហើយរំពឹងថានឹងបន្តកើនឡើងនៅក្នុងឆ្នាំខាងមុខទៀត ។ ដើម្បីទ្រទ្រង់ដល់ការរីកចម្រើននេះការអភិវឌ្ឍប្រព័ន្ធទូទាត់គឺជាការងារអាទិភាពមួយសម្រាប់ធនាគារជាតិនៃកម្ពុជាដើម្បីផ្តល់មធ្យោបាយទូទាត់ជាអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព ងាយស្រួល និងរហ័ស សម្រាប់ការទូទាត់ពាណិជ្ជកម្មទាំងក្នុងប្រទេសនិងក្នុងតំបន់ ។

បច្ចុប្បន្ន ទោះបីជាការប្រើប្រាស់សាច់ប្រាក់ក្នុងសេដ្ឋកិច្ចនៅមានកម្រិតខ្ពស់ក៏ដោយ ក៏ការអភិវឌ្ឍប្រព័ន្ធទូទាត់ត្រូវបានគេមើលឃើញថាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេល

ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយក្នុងនោះរួមមាន ការដាក់ឱ្យប្រើប្រាស់សេវានិងឧបករណ៍ទូទាត់ថ្មីៗជាអេឡិចត្រូនិកដោយគ្រឹះស្ថានធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងអ្នកដំណើរការតតិយភាគីមួយចំនួន ដូចជា សេវាធនាគារតាមអ៊ីនធឺណែតឬសេវាធនាគារចល័ត សេវាទូទាត់សងប្រាក់តាមទូរស័ព្ទចល័ត ប័ណ្ណទូទាត់ (ប័ណ្ណឥណទាននិងឥណពន្ធ) ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត(POS) ។ ការប្រើប្រាស់សេវានិងឧបករណ៍ទាំងនេះមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលបង្ហាញឱ្យឃើញពីកំណើនប្រជាប្រិយភាពលើប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិក ស្របទៅនឹងនិន្នាការនៃការអភិវឌ្ឍប្រព័ន្ធទូទាត់នាពេលបច្ចុប្បន្ន ទាំងក្នុងតំបន់និងក្នុងពិភពលោក ដែលកំពុងតែវិវត្តឆ្ពោះទៅរកយុគសម័យអេឡិចត្រូនិក ។ ស្របពេលជាមួយគ្នានោះ ធនាគារជាតិនៃកម្ពុជាក៏កំពុងបន្តពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិនិងត្រួតពិនិត្យ សំដៅលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធទូទាត់ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ដោយមើលឃើញពីភាពសំខាន់នៃប្រព័ន្ធទូទាត់រាយដូចបានរៀបរាប់ខាងលើនេះ ទើបធនាគារជាតិនៃកម្ពុជាបានខិតខំអភិវឌ្ឍប្រព័ន្ធទូទាត់តាមដំណាក់កាលជាបន្តបន្ទាប់ រួមទាំងការរៀបចំបទប្បញ្ញត្តិនិងក្របខ័ណ្ឌស្ថាប័នឱ្យបានសមស្រប ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជាក់ស្តែង ក្នុងឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានដាក់អោយដំណើរការប្រព័ន្ធផាត់ទាត់ជាតិ ដែលអាចផាត់ទាត់ជាលក្ខណៈមជ្ឈការលើប្រតិបត្តិការទូទាត់អន្តរធនាគារតាមរយៈមូលប្បទានបត្រ និងបញ្ជាទូទាត់អេឡិចត្រូនិក ។

ការអភិវឌ្ឍប្រព័ន្ធសម្រាប់សេវាទូទាត់រហ័សគឺជាគំនិតផ្តួចផ្តើមថ្មីមួយទៀតរបស់ធនាគារជាតិនៃកម្ពុជាក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅប្រទេសកម្ពុជា ។ សេវាថ្មីនេះនឹងអាចឱ្យអតិថិជនទទួលបានមូលនិធិភ្លាមៗ ឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលានិងបង្កើននូវប្រសិទ្ធភាពសេវាទូទាត់តាមរយៈបណ្តាញផ្លូវការ ។ ស្របពេលជាមួយគ្នានោះដែរ ដើម្បីចូលរួមអនុវត្តគោលនយោបាយលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចូលជាសមាជិកសេវានេះ ព្រោះគ្រឹះស្ថានទាំងនោះមានបណ្តាញផ្តល់សេវារបស់ខ្លួនទូលំទូលាយ ដែលអាចឱ្យប្រជាជននៅតាមជនបទចូលរួមប្រើប្រាស់សេវាទូទាត់រហ័សនេះបាន ។ ខ្ញុំសង្ឃឹមថា ការដាក់ឱ្យដំណើរការសេវានេះនឹងផ្តល់ជម្រើសបន្ថែមទៀតសម្រាប់អតិថិជនធ្វើប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់រៀលឆ្លងគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល បង្កើនតម្លាភាពតាមរយៈការទូទាត់ជាអេឡិចត្រូនិក កាត់បន្ថយចរាចរសាច់ប្រាក់នៅលើទីផ្សារ និងបង្កើននូវប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ។

វឌ្ឍនភាពដែលទទួលបាននាពេលបច្ចុប្បន្ននេះគឺជាសមិទ្ធផលពីការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់សងប្រាក់ និងអនុម័តក្របខ័ណ្ឌគតិយុត្តិសមស្របដែលអាចឆ្លើយតបនិងសម្រួលដល់ការរីកចម្រើននៃទីផ្សារ ។ ជាមួយនឹងភាពរីកចម្រើនដូចបានរៀបរាប់ខាងលើ ធនាគារជាតិនៃកម្ពុជាក៏បន្តពង្រឹងសមត្ថភាពក្នុងការអនុវត្តមុខងារគ្រប់គ្រងនិងត្រួតពិនិត្យបន្ថែមទៀត ដើម្បីធានាថា ប្រព័ន្ធទូទាត់សងប្រាក់ដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ទទួលបានការជឿទុកចិត្តពីសាធារណៈ-ជន និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។

បញ្ហាសំខាន់មួយទៀតដែលយើងគួរយកចិត្តទុកដាក់នោះគឺការធ្វើសមាហរណកម្មក្នុងតំបន់ ។ ប្រទេសកម្ពុជាជាសមាជិកសមាគមន៍អាស៊ាន និងបានកំពុងធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ហើយដើម្បីអោយការធ្វើសមាហរណកម្មនេះទទួលបានជោគជ័យទាមទារអោយប្រទេសកម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធទូទាត់សមស្របមួយដែលអាចភ្ជាប់ជាមួយប្រទេសសមាជិកអាស៊ានផ្សេងទៀតសម្រាប់សម្រួលដល់ការទូទាត់ឆ្លងប្រទេសជាអេឡិចត្រូនិកលើសកម្មភាពពាណិជ្ជកម្មរវាងកម្ពុជាជាមួយប្រទេសដែលជាសមាជិកផ្សេងទៀត ។ ការអភិវឌ្ឍប្រព័ន្ធទូទាត់ជាអេឡិចត្រូនិកប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព ដោយប្រើប្រាស់ស្តង់ដាររួមមួយរបស់អាស៊ាន នឹងផ្តល់លទ្ធភាពអោយប្រទេសកម្ពុជាធ្វើសមាហរណកម្មប្រព័ន្ធទូទាត់របស់ខ្លួនជាមួយសមាជិកអាស៊ាន ។ ដូច្នេះ ការអភិវឌ្ឍនិងដាក់អោយដំណើរការសេវាទូទាត់រហ័សថ្ងៃនេះគឺជាជំហានថ្មីមួយទៀតសម្រាប់កម្ពុជាក្នុងការត្រៀមខ្លួនបានកាន់តែប្រសើរ រួមចំណែកគាំទ្រដល់ការចូលរួមសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ជាចុងក្រោយ ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទាំងអស់ សូមផ្តល់ការគាំទ្រ និងយកចិត្តទុកដាក់ជំរុញការប្រើប្រាស់សេវាទូទាត់រហ័សឱ្យបានទូលំទូលាយដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន ។

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ព្រមទាំងក្រុមគ្រួសារ សូមមានសុខភាពល្អកម្លាំងមាំមួន និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច ។

ខ្ញុំសូមប្រកាសដាក់ឱ្យដំណើរការសេវាទូទាត់រហ័សចាប់ពីពេលនេះតទៅ ។

សូមអរគុណ!